# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី១ ឆ្នាំ២០២០
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សេចក្តីផ្តើម:

ឆ្នាំ២០២០គឺជាឆ្នាំទី៥ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ "ជំរុញកំណើនកសិកម្ម ប្រកបដោយការប្រកួតប្រជែងផលិតផលមានគុណភាព សុវត្ថិភាពនិងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចិរភាព"។ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធីអនុកម្មវិធីនិងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២១អង្គភាពថវិកានិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានីខេត្ត។

## (I)-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០

យោងតាមព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។ នៅក្នុងច្បាប់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងឥណទានចំណាយថវិកា ឆ្នាំ២០២០ សរុបមានចំនួន ២៩៩ ០៧៦ លានរៀល ក្នុងនោះ ៖

**(ក) រដ្ឋបាលកណ្តាល៖** បានគ្រោងឥណទានចំណាយថវិកាសរុបចំនួន ១៨៥ ០៧៤ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៦៩ ០៧៤ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ១៦ ០០០ លានរៀល

**(ខ) មន្ទីររាជធានី ខេត្ត** ៖បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន ១១៤ ០០២ លានរៀល

## (II)-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ គិតមកត្រឹមថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តចំណាយតាមអាណត្តិបើកប្រាក់សរុបចំនួន ៥២ ៧៣៦,៩ លានរៀល ស្មើនឹង ១៧,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ក្នុងនោះ(១)រដ្ឋបាលកណ្តាលអនុវត្តបានចំនួន ៣១ ៦២០,៣លានរៀល ស្មើនឹង១៧,១%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (២)មន្ទីររាជធានី ខេត្តអនុវត្តបានចំនួន ២១ ១១៦,៧លានរៀល ស្មើនឹង១៨,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០។

**(ក) រដ្ឋបាលកណ្តាល៖**

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយតាមអាណត្តិបើកប្រាក់របស់រដ្ឋបាលកណ្តាល (២១អង្គភាពថវិកា)សម្រេចបានចំនួន ៣១ ៦២០,៣លានរៀល ដោយក្នុងនោះបានចំណាយលើ(ក)ការទិញ(ជំពូក៦០) អនុវត្តបានចំនួន ១ ១៦០,៦លានរៀល ស្មើនឹង៥,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (ខ)សេវាកម្ម(ជំពូក៦១) អនុវត្តបានចំនួន ២ ៧៧៦,៦ លានរៀលស្មើនឹង៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (គ)បន្ទុកបុគ្គលិក(ជំពូក៦៤ ) អនុវត្តបានចំនួន ២០ ១៥៨,៦ លានរៀល ស្មើនឹង២៧,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (ឃ) ឧបត្ថម្ភធន(ជំពូក៦៥)អនុវត្តបានចំនួន ៧ ៤៩២,៣លានរៀល ស្មើនឹង៣៨,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (ង)ពន្ធនិងអាករ(ជំពូក៦៣) អនុវត្តបានចំនួន ៣២,៣លានរៀល ស្មើនឹង១១,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០។ ទន្ទឹមនឹងនេះរដ្ឋបាលកណ្តាលមិនទាន់បានអនុវត្តចំណាយជំពូក ៦២ (អត្ថប្រយោជន៍សង្គម)និងជំពូក២១(អចលកម្មរូបី) នៅឡើយនៅក្នុងត្រីមាសទី១នេះ។

ម្យ៉ាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្ដាល ឃើញថាទឹកប្រាក់សរុបចំនួន ៣១ ៦២០,៣លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់៖

(១) បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម និងកសិធុរកិច្ច (កម្មវិធីទី១) ចំនួន ១ ៨៥៦,៩លានរៀល ស្មើនឹង៨,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០

(២) ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ ( កម្មវិធីទី២ ) ចំនួន ១ ០៧៧,៤ លានរៀល ស្មើនឹង ៧,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០

(៣) គ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន ៩២៧,៦ លានរៀល ស្មើនឹង ៦,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០

(៤) គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ (កម្មវិធីទី៤) ចំនួន ៨១០,៦លានរៀល ស្មើនឹង៦,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០

(៥) បង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស(កម្មវិធីទី៥) ចំនួន ២៦ ៩៤៧,៨ លានរៀលស្មើនឹង ២៥,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០។

(ខ) **មន្ទីររាជធានី ខេត្ត ៖**

ផ្អែកតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥ រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន ២១ ១១៦,៧លានរៀល ក្នុងនោះចំណាយលើ (ក)ការទិញ(ជំពូក៦០) អនុវត្តបានចំនួន ១ ៨៥៤លានរៀល ស្មើនឹង ១៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន ២ ៨៤១,៧ លានរៀលស្មើនឹង១០,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (គ)បន្ទុកបុគ្គលិក (ជំពូក៦៤ ) អនុវត្តបានចំនួន ១៥ ៦៩០ លានរៀល ស្មើនឹង២២,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (ឃ) អត្ថប្រយោជន៍សង្គម (ជំពូក៦២) អនុវត្តបានចំនួន ៧៣០,៩លានរៀល ស្មើនឹង១០,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ។ ចំពោះការបង់ពន្ធមិនទាន់បានអនុវត្តចំណាយនៅឡើយ។

ម្យ៉ាងទៀតពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុបចំនួន ២១ ១១៦,៧លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តដូចខាងក្រោម៖

ឯកតា: រៀល

| មន្ទីររាជធានី ខេត្ត | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ | ការអនុវត្តត្រីមាសទី១ | %ធៀបច្បាប់ហិរញ្ញវត្ថុ២០២០ |
|---|---|---|---|
| បន្ទាយមានជ័យ | 4,394,500,000 | 669,591,010 | 15.2% |
| បាត់ដំបង | 8,109,900,000 | 2,326,828,500 | 28.7% |
| កំពង់ចាម | 4,679,000,000 | 546,626,685 | 11.7% |
| កំពង់ឆ្នាំង | 4,419,700,000 | 1,043,005,390 | 23.60% |
| កំពង់ស្ពឺ | 6,255,800,000 | 982,600,000 | 15.7% |
| កំពង់ធំ | 6,355,200,000 | 945,002,620 | 14.9% |
| កំពត | 5,508,900,000 | 367,050,000 | 6.7% |
| កណ្ដាល | 7,332,000,000 | 1,842,466,130 | 25.1% |
| កោះកុង | 2,890,000,000 | 535,750,598 | 18.5% |
| ក្រចេះ | 4,303,100,000 | 1,019,067,360 | 23.7% |
| មណ្ឌលគិរី | 3,126,100,000 | 448,218,000 | 14.3% |

| | | | |
|---|---|---|---|
| រាជធានីភ្នំពេញ | 4,028,900,000 | 892,584,300 | 22.2% |
| ព្រះវិហារ | 3,466,700,000 | 631,265,000 | 18.2% |
| ព្រៃវែង | 5,862,200,000 | 789,969,869 | 13.5% |
| ពោធិ៍សាត់ | 4,662,000,000 | 668,745,020 | 14.3% |
| | | | |
| រតនគិរី | 3,611,300,000 | 626,163,020 | 17.3% |
| សៀមរាប | 6,656,700,000 | 1,101,790,470 | 16.6% |
| ព្រះសីហនុ | 3,351,600,000 | 607,077,600 | 18.1% |
| ស្ទឹងត្រែង | 3,521,700,000 | 612,735,840 | 17.4% |
| ស្វាយរៀង | 3,640,700,000 | 551,961,450 | 15.2% |
| តាកែវ | 6,062,200,000 | 1,344,840,936 | 22.2% |
| ឧត្តរមានជ័យ | 3,387,200,000 | 1,155,981,600 | 34.1% |
| កែប | 1,757,900,000 | 292,057,215 | 16.6% |
| ប៉ៃលិន | 2,568,400,000 | 455,692,520 | 17.7% |
| ត្បូងឃ្មុំ | 4,050,300,000 | 659,591,221 | 16.3% |

(III)-**បញ្ហាប្រឈម**

ក្នុងការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី១នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជួបបញ្ហាប្រឈមមួយចំនួនដែលធ្វើឲ្យដំណើរការចំណាយមានការយឺតយ៉ាវ ជាហេតុនាំឲ្យតួលេខនៃការអនុវត្តចំណាយថវិកាសម្រេចបានក្នុងកម្រិតទាប បញ្ហាលំបាកទាំងនោះមាន៖

-ភាពយឺតយ៉ាវក្នុងការលើកគម្រោងចំណាយ ពិសេសការងារលទ្ធកម្មទោះបីក្រសួងបានធ្វើលិខិតជំរុញរំលឹកក៏ដោយ។

-ការផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភាពយឺតយ៉ាវបំផុតដែលនាំឲ្យរាំងស្ទះដល់ការងារអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។

-ឯកសារគាំទ្រសម្រាប់ជម្រះទូទាត់រជ្ជទេយ្យបុរេប្រទានរបស់អង្គភាពថវិកាមួយចំនួនមិនទាន់បំពេញបានគ្រប់គ្រាន់និងទាន់ពេលវេលា។

(IV)-**ទិសដៅអនុវត្តបន្ត**

សម្រាប់ត្រីមាសទី២ អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវខិតខំអនុវត្តចំណាយថវិកា ក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាកររបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី២ ដែលមានទឹកប្រាក់សរុបចំនួន៨១ ៤៦៩ ៤១៧ ០០០រៀល ក្នុងនោះរួមមាន ៖

ឯកតា: រៀល

| ចំណាត់ថ្នាក់សេដ្ឋកិច្ច | រដ្ឋបាលកណ្តាល | មន្ទីររាជធានី ខេត្ត |
|---|---|---|
| ជំពូក ៦០ (ការទិញ) | 6 446 000 000 | 7 092 949 000 |
| ជំពូក ៦១ (សេវាកម្ម) | 13 100 000 000 | 9 133 919 000 |
| ជំពូក ៦៤ (បន្ទុកបុគ្គលិក | 17 800 000 000 | 17 990 447 000 |
| ជំពូក៦២(អត្ថប្រយោជន៍សង្គម) | 0 | 4 758 202 000 |

| | | |
|---|---|---|
| ជំពូក ៦៥ (ឧបត្ថម្ភធន) | 5 130 000 000 | 0 |
| ជំពូក ៦៣ (ពន្ធនិងអាករ) | 0 | 17 900 000 |
| **សរុប** | **42 476 000 000** | **38 993 417 000** |

កិច្ចការបន្ថែមទៀតដែលត្រូវបន្តអនុវត្ត គឺជំរុញទៅដល់គ្រប់អង្គភាពថវិកា លើកសំណើសុំធានាចំណាយពាក់ព័ន្ធនឹងការងារលទ្ធកម្ម សំណើសុំទូទាត់រជ្ជទេយ្យបុរេប្រទានឲ្យបានលឿនពីដើមឆ្នាំ ពិនិត្យកែលម្អសក្ខីបត្រសម្រាប់ការទូទាត់ចំណាយផ្សេងៗ និងសហការសម្របសម្រួលការងារហិរញ្ញវត្ថុរវាងអង្គភាពថវិកាទាំងអស់ ជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**(V)-សេចក្តីសន្និដ្ឋាន**

ឆ្លងតាមការពិនិត្យវាយតម្លៃការអនុវត្តចំណាយថវិការបស់អង្គភាពនៃរដ្ឋបាលកណ្តាល សម្រាប់កម្មវិធីទី១ទី២ទី៣ និងទី៤ សម្រេចបាននៅក្នុងកម្រិតទាប គឺជាលទ្ធផលនៃការអនុវត្តចំណាយតាមនីតិវិធីទូទាត់ត្រង់និងរជ្ជទេយ្យបុរេប្រទានមួយចំនួន រីឯការចំណាយតាមនីតិវិធីលទ្ធកម្មដែលមានទំហំទឹកប្រាក់ច្រើនរួមទាំងការទូទាត់ចំណាយរជ្ជទេយ្យបុរេប្រទានផងនឹងត្រូវធ្វើការទូទាត់ជាបន្តបន្ទាប់ចាប់ពីត្រីមាសទី២ទៅ។ ដោយឡែក ការអនុវត្តចំណាយថវិកាសម្រាប់កម្មវិធីទី៥ សម្រេចបានល្អគឺដោយសារការចំណាយទូទាត់ត្រង់លើប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ។

ចំពោះការអនុវត្តចំណាយថវិការបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមសម្រេចបានក្នុងស្ថានភាពនិងក្នុងកម្រិតប្រហាក់ប្រហែលនិងរដ្ឋបាលកណ្តាលដែរ។ទោះបីជាយ៉ាងនេះក្តីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន៥ខេត្តដែលអនុវត្តចំណាយបានទាបជាងគេ ដែលត្រូវធ្វើការជំរុញនិងកែលំអរបន្ថែមទៀតមានដូចជា៖ ខេត្តកំពត កំពង់ចាម ព្រៃវែង ពោធិ៍សាត់ និងខេត្តមណ្ឌលគិរី។

សរុបសេចក្តីមកការអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី១ ជារួមទទួលបានលទ្ធផលគិតជាភាគរយទាប ប៉ុន្តែបើគិតលើតួលេខនៃការស្នើសុំធានាចំណាយវិញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលកណ្តាល) បានបញ្ជូនសំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សរុបចំនួន ៣៤ ១៣២, ៦ លានរៀល ស្មើនឹង២១%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ដែលជាលទ្ធផលល្អគួរឲ្យកត់សម្គាល់ និងបានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែង ចូលរួមសស្រាក់សស្រាំលើការងារថវិការបស់អង្គភាពថវិកាទាំងនៅរដ្ឋបាលកណ្តាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័កព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០២០

**រដ្ឋលេខាធិការ**

**និងជាប្រធានក្រុមការងាររៀបចំថវិកា**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**យុន្ធ ភូថង**